**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## និរាករណ៍អនុក្រឹត្យ ស្តីពីការធ្វើអនុបយោគផ្ទៃដី ក្នុងភូមិសាស្ត្រ ខេត្តក្រចេះ ខេត្តមណ្ឌលគិរី និងខេត្តសៀមរាប

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈ របស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-យោងសេចក្តីសម្រេចលេខ ១២៥ សសរ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

-យោងលិខិតលេខ ១៧៥៥ សជណ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

## សម្រេច

**មាត្រា ១.-**

១-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១១ សម្រាប់គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច ដាំកៅស៊ូ និងល្ហុងខ្វង លើផ្ទៃដីទំហំ **៧.៨៤៤ (ប្រាំពីរពាន់ប្រាំបីរយសែសិបបួន) ហិកតា** ស្ថិតក្នុងភូមិសាស្ត្រស្រុកចិត្របុរី ខេត្តក្រចេះ របស់ក្រុមហ៊ុន **អ៊ីសធើន អាគ្រោ (ខេមបូឌា) EASTERN AGRO (CAMBODIA) Co.,Ltd**។

២-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យលេខ **៣១** អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ សម្រាប់គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច ដាំដំណាំកសិ-ឧស្សាហកម្ម (ដាំអំពៅ) លើផ្ទៃដីទំហំ **៨.៧២៥ (ប្រាំបីពាន់ប្រាំពីររយម្ភៃប្រាំ) ហិកតា** ស្ថិតក្នុងភូមិសាស្ត្រស្រុកសំបូរ ខេត្តក្រចេះ របស់ក្រុមហ៊ុន **តៃ នីញ ក្រចេះ ស៊ូហ្គើរ (TAY NINH KRATIE SUGAR Co.,Ltd)** ។

៣-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យលេខ **១៤៩** អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ សម្រាប់គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច ដាំកៅស៊ូ និងដំណាំផ្សេងៗ លើផ្ទៃដីទំហំ **៤.០០០ (បួនពាន់) ហិកតា** ស្ថិតក្នុងភូមិសាស្ត្រស្រុកសែនមនោរម្យ និងស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី របស់ក្រុមហ៊ុន **ហេង ហ៊ាង ស៊ីវចាន់ធូ គ្រេនស្តុក** ។

៤-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យលេខ **៧២** អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១២ សម្រាប់គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច ដាំកៅស៊ូ និងដំណាំកសិ-ឧស្សាហកម្ម

លើផ្ទៃដីទំហំ ៧.៧១០ (ប្រាំពីរពាន់ប្រាំពីររយដប់) ហិកតា ស្ថិតក្នុងភូមិសាស្ត្រស្រុកស្វាយលើ ខេត្តសៀមរាប របស់ក្រុមហ៊ុន **លី យេ រ៉ាប់ប៊ើរ** (LY YE RUBBER Co., Ltd) ។

**មាត្រា ២.-**

ផ្ទៃដីដែលគ្របដណ្តប់ដោយបណ្តាអនុក្រឹត្យ ដែលត្រូវបាននិរាករណ៍ដូចមានចែងក្នុង មាត្រា ១ នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តពាក់ព័ន្ធ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលខេត្តក្រចេះ ខេត្តមណ្ឌលគិរី និងខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ៩ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ